Organized by

Supported by

# ព្រឹត្តិបត្រពាណិជ្ជកម្ម

# iTrade Bulletin

## Inside

### Infographic

"Cambodia-United Kingdom Trade Statistics and Facts"

### Policy At Glance

"Food Loss and Waste Analysis: Causes, Prevention and Reduction"

H.E. Mrs. CHAM Nimul & H.E. Dr. TAT Puthsodary

វ៉ុល ០៤ | លេខពិសេស | ខែកញ្ញា ឆ្នាំ២០២៣

VOLUME 04 | SPECIAL EDITION | SEPTEMBER 2023

# ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងចក្រភពអង់គ្លេស

ផ្នែកទី១

សូមស្កេនដើម្បីទាញយក ព្រឹត្តិបត្រពាណិជ្ជកម្ម
ttri.moc
http://ttri.moc.gov.kh/
@ttrimoccambodia

រៀបចំដោយ

គាំទ្រដោយ

## ច្រកទីផ្សារទៅកាន់ចក្រភពអង់គ្លេស

កម្ពុជាអាចទទួល **អត្រាពន្ធអនុគ្រោះសម្រាប់ការនាំចេញ** ទៅកាន់ចក្រភពអង់គ្លេស ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

កម្មវិធីប្រព័ន្ធអនុគ្រោះទូទៅ ផ្តល់ក្រោមក្របខ័ណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក

UK Government

កម្មវិធីប្រព័ន្ធអនុគ្រោះពន្ធ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (DCTS)*

UK Government
កម្មវិធីប្រព័ន្ធអនុគ្រោះពន្ធ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍
*ប្រភព៖ Gov.UK*

### * អំពីប្រព័ន្ធអនុគ្រោះពន្ធ DCTS

១. ប្រព័ន្ធអនុគ្រោះពន្ធ DCTS ចូលជាធរមានថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ជំនួសប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP

២. ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាទទួលបាន **ភាពអនុគ្រោះពន្ធគ្រប់ជ្រុងជ្រោយ** ក្រោមប្រព័ន្ធអនុគ្រោះពន្ធ DCTS ដែលកម្ពុជាទទួលបានកម្រិតអនុគ្រោះដូចខាងក្រោម៖
-ទំនិញរួចពន្ធទាំងស្រុង 0%: **៩៩,៨%** & ទំនិញជាប់ពន្ធ 0% ទៅ ៥%: **0,២%.**

### អំពីចក្រភពអង់គ្លេស (ឆ្នាំ ២០២២)

ផលិតផលក្នុងស្រុកសរុប(ផ.ស.ស)
**៣,០៧** ទ្រីលានដុល្លារ

ផ.ស.ស សម្រាប់មនុស្សម្នាក់
**៥៤ ៦០២** ដុល្លារ

ប្រជាជនសរុប
**៦៦ ៩៧១ ៤១១** នាក់

ពាណិជ្ជកម្មសរុប (ទំនិញ និងសេវាកម្ម)
**៦៩%** នៃផ.ស.ស.




*ប្រភព៖ ធនាគារពិភពលោក*

### អំពីកម្ពុជា និងចក្រភពអង់គ្លេស




10th

ចក្រភពអង់គ្លេសជា**ដៃគូពាណិជ្ជកម្មធំជាងគេទី១០ និងជាដៃគូពាណិជ្ជកម្មធំជាងគេទី២នៅទ្វីបអឺរ៉ុប** របស់កម្ពុជា ក្នុងរយៈពេល៨ខែ ឆ្នាំ២០២៣

ពាណិជ្ជកម្មទ្វេភាគីសម្រេចបាន **៥៨៩ លានដុល្លារ** រយៈពេល ៨ខែ ឆ្នាំ២០២៣ ថយចុះ ១៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២

1.9x

ពាណិជ្ជកម្មទ្វេភាគីឆ្នាំ២០២២ **សឹងតែកើនឡើងទ្វេរដង** ធៀបនឹងពាណិជ្ជកម្មទ្វេភាគីឆ្នាំ២០១២

Import Export

**ការនាំចេញរបស់កម្ពុជា មានចំណែកដល់ទៅ ៩០%** នៃទំហំពាណិជ្ជកម្មទ្វេភាគីសរុបក្នុងរយៈពេល ៨ខែ ឆ្នាំ២០២៣

MOU

ប្រទេសទាំងពីរបានចុះអនុស្សរណៈយោគយោល់គ្នា ស្តីពីការបង្កើតវេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នា ក្នុងឆ្នាំ២០២៣

*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង ITC Trade map*

# ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងចក្រភពអង់គ្លេស

៧ ផ្នែកទី២

សូមស្កេនដើម្បីទាញយកព្រឹត្តិបត្រពាណិជ្ជកម្ម
ttri.moc
http://ttri.moc.gov.kh/
@ttrimoccambodia

រៀបចំដោយ | គាំទ្រដោយ

## ពាណិជ្ជកម្មទ្វេភាគី | ការនាំចេញ និងនាំចូល

**៥៨៩ លានដុល្លារ**
ក្នុងរយៈពេល៨ខែ ឆ្នាំ២០២៣

៦១ លានដុល្លារ
(១០%)




៥២៨ លានដុល្លារ
(៩០%)

### កម្ពុជានាំចូលពីចក្រភពអង់គ្លេស

| | |
|---|---|
| ៦០ លានដុល្លារ | ២០២២ (ត្រឹមខែសីហា) |
| ៦១ លានដុល្លារ | ២០២៣ (ត្រឹមខែសីហា) ▲+2% |

### កម្ពុជានាំចេញទៅចក្រភពអង់គ្លេស

| | |
|---|---|
| ៦២៧ លានដុល្លារ | ២០២២ (ត្រឹមខែសីហា) |
| ៥២៨ លានដុល្លារ | ២០២២ (ត្រឹមខែសីហា) ▼-16% |

## ក្រុមទំនិញសំខាន់ៗនៃពាណិជ្ជកម្មទ្វេភាគី ៨ខែ ឆ្នាំ២០២៣

| កម្ពុជានាំចេញទៅចក្រភពអង់គ្លេស | | | កម្ពុជានាំចូលពីចក្រភពអង់គ្លេស |
|---|---|---|---|
| សម្លៀកបំពាក់និងគ្រឿងបន្ទាប់បន្សំ ដែលធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរ ឬមួយ (HS Code: 61) | ៣១២ លានដុល្លារ | ២១ លានដុល្លារ | យាន ក្រៅពីអយស្ម័យយាន ឬ អយរថអគ្គិសនី និងបំណែកភាគ និងគ្រឿងបន្ទាប់បន្សំរបស់វា (HS Code: 87) |
| សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់មិនធ្វើឡើងពីការចាក់ដោយម្ជុលពីរ ឬមួយ (HS Code: 62) | ៩៨ លានដុល្លារ | ១៤ លានដុល្លារ | រ៉េអាក់ទ័រនុយក្លេអ៊ែរ ធុងផលិតចំហាយទឹក ម៉ាស៊ីន និងឧបករណ៍មេកានិក បំណែកភាគរបស់វា (HS Code: 84) |
| ស្បែកជើង ស្រោមជើង និងវត្ថុប្រហាក់ប្រហែល (HS Code: 64) | ៤៩ លានដុល្លារ | ៩ លានដុល្លារ | កាកសំណល់ពីឧស្សាហកម្មម្ហូបអាហារ ចំណីកែច្នៃសម្រាប់សត្វ (HS Code: 23) |
| យាន ក្រៅពីអយស្ម័យយាន ឬ អយរថអគ្គិសនី និងបំណែកភាគ និងគ្រឿងបន្ទាប់បន្សំរបស់វា (HS Code: 87) | ២៣ លានដុល្លារ | ៤ លានដុល្លារ | សារធាតុសម្លាប់ស្បែក ឬជ្រលក់ពណ៌ ថ្នាំសម្លាប់ស្បែក និងដេរីវេរបស់វា (HS Code: 32) |
| ធញ្ញជាតិ (HS Code: 10) | ១១ លានដុល្លារ | ៣ លានដុល្លារ | ភេសជ្ជៈ ស្រា និងទឹកខ្មេះ (HS Code: 22) |




● កម្ពុជានាំចេញទៅចក្រភពអង់គ្លេស
● កម្ពុជានាំចូលពីចក្រភពអង់គ្លេស

*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

# CAMBODIA–UNITED KINGDOM
# TRADE STATISTICS AND FACTS
## Part 1

Scan to access iTrade Bulletin
ttri.moc
http://ttri.moc.gov.kh/
@ttrimoccambodia

Organized by

Supported by

## Market Access to the United Kingdom

Cambodia got **export preferential tariff treatment** to the UK via the following frameworks:

The Generalized System of Preferences under the WTO framework

UK Government

Comprehensive Preferences under the Developing Countries Trading Scheme (DCTS)*

UK Government
**Comprehensive Preferences under the Developing CountriesTrading Scheme**
(Source: Gov. UK)

### *ABOUT THE DCTS

1. DCTS entered into force on 19 June 2023, replacing the UK's GSP Scheme.
2. As a Least Developed Country (LDC), Cambodia enjoys "**Comprehensive Preferences**" under the DCTS, where Cambodia can receive preferential tariffs as follows:
   -Tariff free products (0%): **99.8%** & Products with 0% to 5% tariffs: **0.2%.**

## ABOUT THE UK (2022)

Gross Domestic Products
**$ 3.07 Trillion**

GDP Per Capita
**$ 54,602**

Total Population
**66,971,411**

Total Trade (Goods and Services)
**69% of GDP**

(Source: World Bank)

## ABOUT CAMBODIA AND THE UK

10th — The UK is Cambodia's **10th largest world trade partner** and **2nd largest trade partner in Europe** in the 8 months of 2023

Bilateral trade reached **$ 589 million** in the 8 months of 2023 with a 14% drop from previous year

1.9x — The total 2022 bilateral trade **has almost doubled** the bilateral trade exchange in 2012

Import / Export — **Cambodia's exports accounted for 90%** of the bilateral trade from January to August of 2023

MOU — Both countries signed **MoU on Cambodia-UK Joint Trade and Investment Forum** in 2023

*(Source: General Department of Customs and Excise of Cambodia & ITC Trade Map)*

# CAMBODIA–UNITED KINGDOM
## TRADE STATISTICS AND FACTS
### *Part 2*

Scan to access iTrade Bulletin
ttri.moc
http://ttri.moc.gov.kh/
@ttrimoccambodia

Organized by Supported by

## Bilateral Trade | import & export







Cambodia **imported from** the UK

$ 60 mil. 2022 (By Aug)

$ 61 mil. 2023 (By Aug) ▲+2%

Cambodia **exported to** the UK

$ 627 mil. 2022 (By Aug)

$ 528 mil. 2023 (By Aug) ▼-16%

## Key Commodity Groups | 2023 (Jan - Aug)

| Cambodia's Export to the UK | | Cambodia's Import from the UK | |
|---|---|---|---|
| Articles of apparel and clothing accessories, knitted or crocheted *(HS Code: 61)* | $ 312 mil. | $ 21 mil. | Vehicles other than railway or tramway rolling-stock, and parts and accessories thereof *(HS Code: 87)* |
| Articles of apparel and clothing accessories, not knitted or crocheted *(HS Code: 62)* | $ 98 mil. | $ 14 mil. | Nuclear reactors, boilers, machinery and mechanical appliances; parts thereof *(HS Code: 84)* |
| Footwear, gaiters and the like *(HS Code: 64)* | $ 49 mil. | $ 9 mil. | Residues and waste from the food industries; prepared animal fodder *(HS Code: 23)* |
| Vehicles other than railway or tramway rolling-stock, and parts and accessories thereof *(HS Code: 87)* | $ 23 mil. | $ 4 mil. | Tanning or dyeing extracts; tannins and their derivatives *(HS Code: 32)* |
| Cereals *(HS Code: 10)* | $ 11 mil. | $ 3 mil. | Beverages, spirits and vinegar *(HS Code: 22)* |




● Cambodia's Export to the UK
● Cambodia's Import from the UK

*(Source: General Department of Customs and Excise of Cambodia)*

## យុទ្ធសាស្ត្របញ្ចកោណ កិច្ចព្រមព្រៀងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ (BRI) ត្រូវបានសរសើរ

អ្នកជំនាញផ្នែកទំនាក់ទំនងអន្តរជាតិ និងវិទ្យាសាស្ត្រនយោបាយបានគាំទ្រនូវការបន្សុីគ្នា រវាងយុទ្ធសាស្ត្របញ្ចកោណរបស់កម្ពុជា និងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ (BRI) របស់ចិន ដែលត្រូវបានឯកភាពគ្នានាពេលថ្មីៗនេះ។ សេចក្តីសម្រេចនេះធ្វើឡើងអំឡុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ទៅកាន់ប្រទេសចិន។ អ្នកជំនាញបានគូសបញ្ជាក់ពីសារៈសំខាន់នៃផលប្រយោជន៍សេដ្ឋកិច្ចក្នុងទំនាក់ទំនងអន្តរជាតិនាសម័យទំនើប ដោយសង្កត់ធ្ងន់លើអត្ថប្រយោជន៍សេដ្ឋកិច្ចដែលកម្ពុជាទទួលបាន ក្រោយការបន្សុីគ្នាទៅនឹងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវនេះ។ គេជឿជាក់ថាកម្ពុជានឹងប្រកាន់ជំហដើម្បីទទួលបានផលប្រយោជន៍ជាច្រើនពីការបន្សុីគ្នានេះ និងមើលឃើញថានេះជាជំហានវិជ្ជមានសម្រាប់ការអភិវឌ្ឍប្រទេស។ ខណៈកម្ពុជាខិតខំពង្រឹងទំនាក់ទំនងជាមួយចិន អ្នកជំនាញក៏បានព្រមានអំពីតម្រូវការនានាសម្រាប់អនុវត្តបន្តិចម្តងៗប្រកបដោយភាពប្រុងប្រយ័ត្ន និងបានផ្តល់អនុសាសន៍ឱ្យកម្ពុជាពង្រឹងសមត្ថភាពផ្ទៃក្នុងរបស់ខ្លួនជាមុនសិនសម្រាប់ការអភិវឌ្ឍប្រកបដោយតុល្យភាព។ យុទ្ធសាស្ត្របញ្ចកោណផ្តោតលើទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍ រួមទាំងការអភិវឌ្ឍធនធានមនុស្ស ពិពិធកម្មសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍឌីជីថល។ កិច្ចព្រមព្រៀង BRI ដែលត្រូវបានផ្តួចផ្តើមឡើងដោយចិនកាលពីឆ្នាំ២០១៣ ក្នុងគោលបំណងលើកកម្ពស់ការតភ្ជាប់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងតំបន់។ *ប្រភព៖* *The Phnom Penh Post*

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អំពាវនាវឱ្យខេត្ត ក្វាងស៊ីវិនិយោគបន្ថែម

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានស្នើឱ្យមានការបង្កើនការវិនិយោគរបស់ចិន នៅក្នុងវិស័យសំខាន់ៗជាច្រើននៃសេដ្ឋកិច្ចរបស់កម្ពុជា រួមមាន កសិកម្ម ការថែទាំសុខភាពសាធារណៈ ទេសចរណ៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំ និងកីឡា។ ក្នុងជំនួបជាមួយលោក លៀវ នីន លេខាគណៈកម្មាធិការបក្សកុម្មុយនិស្តចិន ប្រចាំតំបន់ស្វយ័តក្វាងស៊ី ដែលបានប្រារព្ធឡើងក្នុងអំឡុងពិព័រណ៍ចិន-អាស៊ាន នៅទីក្រុងណាននីង សម្តេចមហាបវរធិបតី បានស្នើឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែទូលំទូលាយ និងការហោះហើរត្រង់បន្ថែមទៀតរវាងកម្ពុជា និងក្វាងស៊ី។ សម្តេចធិបតី ក៏បានជំរុញឱ្យមានការសិក្សាពីអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីការសាងសង់សួនឧស្សាហកម្មកម្ពុជា-ចិន ដោយផ្តោតលើសេដ្ឋកិច្ចឌីជីថល និងកសិកម្មឆ្លាតវៃ។ លោក លៀវ បានបង្ហាញចំណាប់អារម្មណ៍របស់ខេត្តក្វាងស៊ី ក្នុងកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយកម្ពុជា ដោយសង្កត់ធ្ងន់លើកិច្ចសហការដែលមានស្រាប់របស់ពួកគេក្នុងវិស័យពាណិជ្ជកម្ម ការថែទាំសុខភាព បច្ចេកវិទ្យា និងការបណ្តុះបណ្តាលធនធានមនុស្ស។ សម្តេចធិបតី បានធានាដល់អ្នកវិនិយោគអំពីសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់កម្ពុជា ដោយគូសបញ្ជាក់ពីការធានាលើផ្នែកសន្តិសុខ ហើយការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយប្រទេសចិនបានរួមចំណែកធំជាងគេ។ *ប្រភព៖* *The Phnom Penh Post*

## សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីបានមានប្រសាសន៍ពីការចូលរួមរបស់វិស័យឯកជនក្នុងការពង្រីកមូលដ្ឋានសេដ្ឋកិច្ចក្នុងកិច្ចព្រមព្រៀងអាសិប

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ ពីសារៈសំខាន់នៃការចូលរួមរបស់វិស័យឯកជនក្នុងការអនុវត្តកិច្ចព្រមព្រៀងអាសិប។ ថ្លែងក្នុងកិច្ចប្រជុំកំពូលស្តីពីធុរកិច្ច កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអាសិប លើកទី៣ នៅប្រទេសចិន សម្តេចបានសង្កត់ធ្ងន់ថា វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីប៉ាស៊ីហ្វិកមួយនេះ។ កិច្ចព្រមព្រៀង អាសិប រួមមានប្រទេសសមាជិកចំនួន១៥ ស្មើនឹងប្រមាណ ៣០% នៃចំនួនប្រជាជនសរុប និងផលិតផលក្នុងស្រុកសរុប របស់ពិភពលោក ហើយក៏ជាប្លុកពាណិជ្ជកម្មដ៏ធំបំផុតក្នុងពិភពលោក។ សម្តេចធិបតី ក៏បានលើកឡើងពីតម្រូវការក្នុងការជំរុញពាណិជ្ជកម្មសេវាកម្ម ជាពិសេសពាណិជ្ជកម្មឌីជីថល ក្នុងក្របខ័ណ្ឌ អាសិប ផងដែរ។ សម្តេចធិបតី បានអំពាវនាវឱ្យរាប់បញ្ចូលទាំងអាជីវកម្មចាប់ផ្តើមថ្មី និងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងលើកទឹកចិត្តឱ្យមានការពង្រីកសមាជិកភាព ដើម្បីពង្រឹងទំនាក់ទំនងជាមួយដៃគូសក្តានុពលនានាដែលមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀង។ លើសពីនេះ សម្តេចធិបតី បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសប្រកបដោយបរិយាប័ន្ន សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួច។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាពង្រឹងតួនាទីរបស់ខ្លួននៅក្នុងអាស៊ាន ដើម្បីជំរុញកំណើនវិស័យឯកជន និងការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកល ជាមួយនឹងការជំរុញកំណើននៃការនាំចេញ។ *ប្រភព៖* [Khmer Times]

## សហព័ន្ធស្រូវអង្ករកម្ពុជា រាយការណ៍ពីការនាំចេញអង្ករដែលនឹងឈានដល់១ លានតោន នៅឆ្នាំ២០២៥

កម្ពុជាកំពុងបោះជំហានគួរឱ្យកត់សំគាល់ទៅរកគោលដៅនាំចេញអង្ករ១ លានតោនក្នុងមួយឆ្នាំ នៅឆ្នាំ២០២៥ ដោយក្នុងរយៈពេល៨ខែដំបូងនៃឆ្នាំនេះ កម្ពុជាបាននាំចេញអង្ករលើសពី ៤០ ម៉ឺនតោនរួចហើយ។ កត្តាសំខាន់ៗដែលរួមចំណែកដល់សមិទ្ធិផលនេះ រួមមានផែនការរបស់ឥណ្ឌូនេស៊ីក្នុងការនាំចូលអង្ករពីកម្ពុជាចំនួន ២៥ ម៉ឺនតោនក្នុងមួយឆ្នាំ ជាមួយនឹងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីពាណិជ្ជកម្មអង្ករដែលនឹងត្រូវចុះហត្ថលេខានៅឆ្នាំ២០២៤ ខាងមុខនេះ។ លើសពីនេះ ហ្វីលីពីនក៏បានសម្តែងចំណាប់អារម្មណ៍ក្នុងការនាំចូលអង្ករពីកម្ពុជាផងដែរ ដែលនេះបង្ហាញពីការធ្វើពិពិធកម្មអង្ករទៅទីផ្សារនាំចេញសក្តានុពលដទៃទៀត។ សហព័ន្ធស្រូវអង្ករកម្ពុជា បានរាយការណ៍ថាកម្ពុជាបាននាំចេញអង្ករប្រមាណ ៥៨% នៃផែនការនាំចេញអង្ករឆ្នាំ ២០២៣ គិតចាប់ពីខែមករាដល់ខែសីហា ដែលនេះបង្ហាញពីការកើនឡើងនៃការនាំចេញអង្ករ។ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការលើកកម្ពស់ផលិតភាព ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការអនុវត្តវិធានការត្រួតពិនិត្យគុណភាព បានជំរុញសមត្ថភាពផលិតកម្មស្រូវរបស់ខ្លួន។ កម្ពុជាមានទីតាំងភូមិសាស្ត្រ និងអាកាសធាតុអំណោយផល និងដីមានជីជាតិ បានបន្ថែមនូវសក្តានុពលជាប្រទេសឈានមុខគេដ៏សំខាន់នៅក្នុងទីផ្សារអង្ករពិភពលោក។ *ប្រភព៖* [Khmer Times]

## ប្រទេសជាសមាជិក BRICS ទម្លាក់ប្រាក់ដុល្លារក្នុងការជួញដូរប្រេង

ក្រុមប្រទេស BRICS កំពុងប្រឈមមុខនឹងការពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារអាម៉េរិកក្នុងការធ្វើពាណិជ្ជកម្មពិភពលោក ដោយជម្រុញការប្រើប្រាស់រូបិយប័ណ្ណផ្ទាល់ខ្លួនរបស់ពួកគេវិញ។ ថ្មីៗនេះ ឥណ្ឌាបានបោះជំហានក្នុងទិសដៅនេះ ដោយប្រើប្រាក់រ៉ូពី ជំនួសឱ្យប្រាក់ដុល្លារអាម៉េរិក ក្នុងការទិញប្រេង ១ លានបារ៉ែល និងអេមីរ៉ាតអារ៉ាប់រួម ឥណ្ឌាក៏កំពុងពិភាក្សាជាមួយនឹងអារ៉ាប៊ីសាអូឌីត អំពីការទូទាត់ប្រតិបត្តិការប្រេងជារូបិយវត្ថុក្នុងស្រុករបស់ពួកគេ។ ចំណាត់ការនេះ មានគោលបំណងអះអាងនូវស្វ័យភាពសេដ្ឋកិច្ចសម្រាប់ក្រុមប្រទេស BRICS និងកាត់បន្ថយការពឹងផ្អែកលើប្រាក់ដុល្លារអាម៉េរិក ដែលអាចកាត់បន្ថយតម្រូវការជាសកលរបស់ខ្លួនពីប្រាក់ដុល្លារអាម៉េរិក។ ឥទ្ធិពលនៃចលកនេះអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចអាម៉េរិក និងផ្លាស់ប្តូរតុល្យភាពអំណាចក្នុងនយោបាយពិភពលោក និងប្រទេសជាសម្ព័ន្ធមិត្ត។ សកម្មភាពរបស់សម្ព័ន្ធមិត្ត BRICS នេះ បង្ហាញពីបំណងចង់រៀបចំនូវវិធានសេដ្ឋកិច្ចឡើងវិញ ហើយបង្កើនភាពឯករាជ្យរបស់ពួកគេ។ *ប្រភព៖* **CRYPTOPOLITAN**

## ប្រទេសចិនជំរុញឱ្យសហភាពអឺរ៉ុបធានាថាការយកពន្ធគយលើកាបូនថ្មី អនុលោមតាមច្បាប់អង្គការពាណិជ្ជកម្មពិភពលោក

ប្រទេសចិនបានជំរុញឱ្យសហភាពអឺរ៉ុប (EU) ធានាថាពន្ធគយដែលខ្លួនបានស្នើឡើង ពី ២០% ទៅ ៣៥% លើការនាំចូលកាបូនកម្រិតខ្ពស់ដូចជាដែក រ៉ែដែក និងស៊ីម៉ងត៍ស្របតាមបទប្បញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងមិនបំពានលើគោលនយោបាយពាណិជ្ជកម្មបៃតងជាសកល។ ប្រទេសចិន រួមជាមួយនឹងសមាជិក WTO ផ្សេងទៀតបានសម្តែងនូវការព្រួយបារម្ភអំពីយន្តការកែតម្រូវកម្រិតកាបូន (CBAM) របស់សហភាពអឺរ៉ុប ដែលត្រូវបានធ្វើឡើងដើម្បីការពារឧស្សាហកម្មអឺរ៉ុប ពីការកាត់បន្ថយតម្លៃ និងការនាំចូលដែលប៉ះពាល់តិចតួចដល់បរិស្ថាន។ ប្រទេសចិនលើកទឹកចិត្តឱ្យសហភាពអឺរ៉ុប ជៀសវាងវិធានការការពារនិយម និងរបាំងពាណិជ្ជកម្មបៃតង ហើយមានបំណងចូលរួមក្នុងកិច្ចពិភាក្សាពហុភាគី ស្តីពីពាណិជ្ជកម្មបៃតងក្នុងក្របខ័ណ្ឌ WTO។ ខណៈប្រទេសចិនមានគោលដៅសម្រេចឱ្យបាននូវសេដ្ឋកិច្ចបៃតង ប្រទេសនេះត្រូវប្រឈមនឹងការទទួលខុសត្រូវដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ។ សហភាពអឺរ៉ុបគ្រោងនឹងអនុវត្តការយកពន្ធគយលើការនាំចូលទំនិញមានផ្ទុកសារជាតុកាបូនកម្រិតខ្ពស់ចាប់ពីឆ្នាំ២០២៦ ដោយលើកឡើងថាខ្លួនគោរពតាមច្បាប់ WTO ។ *ប្រភព៖* **REUTERS**

## សេដ្ឋកិច្ចសកលឈានចូលដល់សករាជអស្ថិរភាព

ក្រុមហ៊ុនសាជីវកម្មសកលកំពុងបង្កើនការប្រើប្រាស់ពាក្យ "ភូមិសាស្ត្រនយោបាយ" ទៅក្នុងយុទ្ធសាស្ត្រអាជីវកម្មរបស់ពួកគេ ដោយបានលើកឡើងនូវពាក្យនេះជាញឹកញាប់នៅក្នុងឯកសារសាជីវកម្ម និងការស្វែងរកប្រាក់ចំណូល។ ភាពតានតឹងរវាងអាម៉េរិក-ចិន ជម្លោះអ៊ុយក្រែន និងការផ្តោតសំខាន់ខ្លាំងលើផលប្រយោជន៍ជាតិ បាននាំឱ្យមានការផ្លាស់ប្តូរទាំងនេះ។ ក្រុមហ៊ុននានា វិនិយោគតែក្នុងប្រទេសដែលសម្របតាមផលប្រយោជន៍ភូមិសាស្ត្រនយោបាយរបស់គេតែប៉ុន្នោះ ដែលនេះបង្ហាញពីការរៀបចំពិភពលោកទៅជាប្លុកគូប្រជែង ដោយផ្អែកលើការបោះឆ្នោតរបស់អង្គការសហប្រជាជាតិស្តីពីការឈ្លានពានរបស់រុស្ស៊ីលើអ៊ុយក្រែន។ ផលវិបាកសេដ្ឋកិច្ចដែលនៅតែមានភាពមិនប្រាកដប្រជា កំពុងធ្វើឱ្យប្រែប្រួលទិដ្ឋភាពសេដ្ឋកិច្ចសកល។ កត្តាភូមិសាស្ត្រនយោបាយកំពុងជះឥទ្ធិពលលើពាណិជ្ជកម្ម ការវិនិយោគ និងខ្សែច្រវាក់ផ្គត់ផ្គង់ ដែលអាចនាំឱ្យមានអតិផរណា ការធ្លាក់ចុះនវានុវត្តន៍ និងការកើនឡើងវិសមភាពសកល។ ទោះជាមានការផ្លាស់ប្តូរក៏ពិភពលោកនៅតែផ្សារភ្ជាប់គ្នា ទំនាក់ទំនងសេដ្ឋកិច្ចនៅតែមានដំណើរការ ដោយប្រទេស និងក្រុមហ៊ុនសាជីវកម្មនៅតែមានបំណងលក់ឱ្យគ្នាទៅវិញទៅមក។ *ប្រភព៖* **Bloomberg**

## តើអ្វីជាក្រុមប្រទេស G20 ហើយសម្រេចបានលទ្ធផលអ្វីខ្លះពីកិច្ចប្រជុំកំពូលនៅទីក្រុងញ៉ូដេលី?

ក្រុមប្រទេស G20 ដែលតំណាងឱ្យ ៨៥% នៃទិន្នផលសេដ្ឋកិច្ចពិភពលោក និង ៧៥% នៃពាណិជ្ជកម្មសកល បានរៀបចំកិច្ចប្រជុំកំពូលនៅទីក្រុងញ៉ូដេលី ប្រទេសឥណ្ឌា។ ក្នុងកិច្ចប្រជុំកំពូលនោះ សហភាពអាហ្វ្រិកត្រូវបានអញ្ជើញឱ្យចូលរួម ដើម្បីក្លាយជាសមាជិកអចិន្ត្រៃយ៍ ដែលតំណាងឱ្យ៥៥ ប្រទេសនៃទ្វីបអាហ្វ្រិក។ ក្រុមប្រទេស G20 ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ គឺជាវេទិកាសម្រាប់រដ្ឋមន្ត្រីហិរញ្ញវត្ថុដោះ

ស្រាយបញ្ហាស្ថិរភាពសេដ្ឋកិច្ច ក្រោយមកបានពង្រីកការយកចិត្តទុកដាក់ លើបញ្ហាបម្រែបម្រួលអាកាសធាតុ និងថាមពលប្រកបដោយនិរន្តរភាព។ លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំកំពូលនៅទីក្រុងញ៉ូដេលី រួមមានសេចក្ដីប្រកាសរួមមួយដែលបានថ្កោលទោសផលប៉ះពាល់នៃជម្លោះអ៊ុយក្រែន មកលើសន្តិសុខស្បៀង និងថាមពលសកល ទោះបីមិនមានការរិះគន់ចំៗទៅលើប្រទេសរុស្ស៊ីក៏ដោយ។ បណ្ដាញផ្លូវដែក និងផ្លូវដឹកជញ្ជូនថ្មីត្រូវបានប្រកាសដោយសហរដ្ឋអាម៉េរិក ឥណ្ឌា អារ៉ាប៊ីសាអូឌីត និងសហភាពអឺរ៉ុប ដើម្បីជំរុញពាណិជ្ជកម្ម និងទប់ទល់នឹងគំនិតផ្តួចផ្តើមគំនិតផ្តួចផ្តើម "ខ្សែក្រវាត់ និងផ្លូវ" របស់ចិន។ *ប្រភព៖* **BBC**

## ការធ្វើឱ្យប្រសើរឡើងនៃសកលភាវូបនីយកម្ម ដើម្បីអនាគតប្រកបដោយសុវត្ថិភាព បរិយាប័ន្ន និងចីរភាព

របាយការណ៍ពាណិជ្ជកម្មពិភពលោក ឆ្នាំ២០២៣ បោះផ្សាយដោយ WTO ពិនិត្យលើតួនាទីនៃពាណិជ្ជកម្មអន្តរជាតិ ក្នុងការជំរុញបរិយាកាសពិភពលោកប្រកបដោយសុវត្ថិភាព បរិយាប័ន្ន និងនិរន្តរភាព។ របាយការណ៍នេះ បានគូសបញ្ជាក់អំពីសារៈសំខាន់នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីដ៏រឹងមាំក្នុងការធានាបាននូវសន្តិសុខសេដ្ឋកិច្ច ដែលត្រូវបានគេមើលឃើញក្នុងអំឡុងជំងឺរាតត្បាត។ នោះបានបង្ហាញពីសក្ដានុពលនៃវិស័យពាណិជ្ជកម្ម ក្នុងការលើកកម្ពស់បរិយាប័ន្ន និងការកាត់បន្ថយភាពក្រីក្រ ដោយសង្កត់ធ្ងន់លើតម្រូវការការគាំទ្រដោយគោលនយោបាយក្នុងស្រុក។ របាយការណ៍នេះក៏បានស្វែងយល់ពីតួនាទីនៃវិស័យពាណិជ្ជកម្ម ក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុក្នុងក្របខ័ណ្ឌសមាហរណកម្មបន្ថែម។ តួនាទីរបស់ WTO ក្នុងការលើកកម្ពស់សកលភាវូបនីយកម្មឡើងវិញ ជាពិសេសតាមរយៈកិច្ចព្រមព្រៀង មានដូចជាកិច្ចសម្រួលពាណិជ្ជកម្ម ដែលត្រូវបានគូសបញ្ជាក់ពីសារៈសំខាន់ នៃការកាត់បន្ថយថ្លៃដើមពាណិជ្ជកម្មបន្ថែមទៀតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម និងសេវាកម្ម ដើម្បីសម្រេចបាននូវអនាគតប្រកបដោយសុវត្ថិភាព បរិយាប័ន្ន និងចីរភាព។ *ប្រភព៖* **WTO Blog**

## អនាគតនៃ អង្គការពាណិជ្ជកម្មពិភពលោកជម្រើសនៃកិច្ចព្រមព្រៀង Multilateral ឬក៏ Plurilateral ?

កាលពីខែមិថុនា ឆ្នាំ២០២២ អង្គការពាណិជ្ជកម្មពិភពលោក (WTO) សម្រេចបានជោគជ័យដ៏កម្រមួយ ដោយបានបញ្ចប់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីជាច្រើន រួមមានការលើកលែងចំពោះវ៉ាក់សាំងកូវីដ-១៩ បទប្បញ្ញត្តិស្ដីពីការឧបត្ថម្ភធនលើវិស័យជលផល កតិកាសញ្ញាសន្តិសុខស្បៀង និងការបន្តផ្អាកយកពន្ធគយពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក។ កិច្ចព្រមព្រៀងទាំងនោះបង្ហាញពីសក្ដានុពលសម្រាប់សកម្មភាពជាសមូហភាព នៃប្រទេសសមាជិកទាំង ១៦៤ របស់ WTO។ ទោះជាយ៉ាងណា កំឡុងពេលមានកំណើនសេដ្ឋកិច្ចជាតិនិយម និងការធ្លាក់ចុះនូវការប្ដេជ្ញាចិត្តចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ សមត្ថភាពរបស់ WTO ដើម្បីសម្រេចបាននូវ សេរីភាវូបនីយកម្មពាណិជ្ជកម្មដ៏ទូលំទូលាយតាមរយៈការឯកភាពជាឯកច្ឆន្ទ ហាក់នៅមានកម្រិត។ ដើម្បីរក្សាការប្ដេជ្ញាចិត្តរបស់ខ្លួនចំពោះប្រព័ន្ធពហុនិយម WTO ត្រូវតែអនុម័តវិធីសាស្ត្រថ្មី។ WTO គួរតែលើកទឹកចិត្តឱ្យមានកិច្ចព្រមព្រៀង Plurilateral នៅក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន ជាជាងទាមទារការសម្រេចជាឯកច្ឆន្ទលើកិច្ចព្រមព្រៀងនានា។ នាពេលអនាគតកិច្ចព្រមព្រៀង Plurilateral ទាំងនេះអាចវិវឌ្ឍន៍ទៅជាកិច្ចព្រមព្រៀង Multilateral ដែលគ្របដណ្ដប់ដល់សមាជិកទាំងអស់។ គំនិតផ្តួចផ្តើមទាំងនោះ គឺជាជោគជ័យ ដែលនាំឱ្យមានការយល់ស្របជាឯកច្ឆន្ទ និងការទទួលយកកាន់តែទូលំទូលាយ។ *ប្រភព៖* **CATO Institute**

## Pentagonal Strategy, BRI Agreement Commended

Experts in international relations and political science have endorsed the recent alignment of Cambodia's Pentagonal Strategy with China's Belt and Road Initiative (BRI). The agreement was reached during Prime Minister Hun Manet's state visit to China. Experts highlight the importance of economic interests in modern international relations, emphasizing the economic benefits of aligning with the BRI. They believe Cambodia stands to gain more from this alignment and see it as a positive step for the country's development. While Cambodia seeks to strengthen its ties with China, experts also caution the need for gradual and careful implementation and recommend strengthening internal capacities for balanced development. The Pentagonal Strategy focuses on various aspects of development, including human capital, economic diversification, competitiveness, and digital development. The BRI, initiated by China in 2013, aims to enhance connectivity and infrastructure development across regions. ***Source: The Phnom Penh Post***

## Manet Calls for Additions to Guangxi Zhuang Investment

Prime Minister Hun Manet has proposed increased Chinese investment in various critical sectors of Cambodia's economy, including agriculture, public healthcare, tourism, vocational training, education, and sports. During a meeting with Liu Ning, secretary of the Communist Party of China (CPC) committee for the Guangxi Zhuang Autonomous Region, held during the China-ASEAN Expo in Nanning, Manet suggested broader collaboration and more direct flights between Cambodia and Guangxi. He also urged the exploration of a memorandum of understanding (MoU) on constructing Cambodia-China industrial parks, with a focus on the digital economy and smart agriculture. Liu expressed Guangxi's interest in further cooperation with Cambodia, emphasizing their existing collaborations in trade, healthcare, technology, and human resource training. Manet assured investors of Cambodia's public order and political stability, highlighting the absence of security concerns, and noted that foreign direct investment (FDI) in Cambodia has seen significant growth, with China being the largest contributor. ***Source: The Phnom Penh Post***

## Incorporate Private Sector in Enlarging RCEP Economic Base, Says PM

Prime Minister Hun Manet of Cambodia has emphasized the importance of involving the private sector in expanding the Regional Comprehensive Economic Partnership (RCEP). Speaking at the Third RCEP Economic and Trade Cooperation Business Summit in China, he stressed that the private sector plays a crucial role in implementing this Asia-Pacific free trade agreement. RCEP, comprising 15 member countries and accounting for 30% of the world's population and GDP, is the largest trade bloc globally. PM Hun Manet also highlighted the need to promote trade in services, especially digital commerce, within RCEP. He called for the inclusion of start-ups and small and medium-sized enterprises in the agreement and encouraged the expansion of membership to strengthen ties with potential external partners. Additionally, he emphasized the importance of inclusivity and economic and technical cooperation, particularly for least-developed countries. Cambodia's government is committed to enhancing its role in ASEAN, fostering private sector growth, and promoting regional and global economic integration, with exports on the rise. ***Source: Khmer Times***

## Cambodian Rice Federation Reports Record Rice Exports, on Track to Reach 1 Million Tonnes by 2025

Cambodia is making significant strides toward its goal of exporting 1 million tonnes of rice annually by 2025, with rice exports exceeding 400,000 tonnes in the first eight months of the year. Key factors contributing to this achievement include Indonesia's plan to import 250,000 tonnes of rice from Cambodia each year, with a Memorandum of Understanding (MoU) on rice trade set to be signed in 2024. Additionally, countries like the Philippines have expressed interest in importing Cambodian rice, diversifying potential markets. The Cambodian Rice Federation reported that the country exported 58% of its 2023 annual export plan between January and August, showcasing substantial growth in the rice trade. Cambodia's efforts to improve productivity, modernize agriculture infrastructure, and implement quality control measures have boosted its rice production capabilities. The nation's favourable geographic location, fertile land, and climate further support its potential as a significant player in the global rice market. ***Source: Khmer Times***

## BRICS Nations Dump Dollar in Oil Trades

BRICS nations are challenging the dominance of the US dollar in global trade by promoting the use of their local currencies. India has recently made significant strides in this direction, purchasing 1 million barrels of oil and gold from the UAE using the Rupee instead of the US dollar. India is also in discussions with Saudi Arabia about settling oil transactions in their local currencies. This move aims to assert economic autonomy for BRICS nations and reduce reliance on the US dollar, potentially diminishing its global demand. The ripple effects could impact the US economy and shift the balance of power in global politics and alliances. The BRICS alliance's bold actions signal a desire to rewrite established economic rules and assert their independence. ***Source: CRYPTOPOLITAN***

## China Urges EU to Ensure New Carbon Tax Complies with WTO Rules

China has urged the European Union (EU) to ensure that its proposed tariffs of 20% to 35% on high-carbon imports like steel, iron ore, and cement align with World Trade Organization (WTO) regulations and do not violate global green trade policies. China, along with other WTO members, has expressed concerns about the EU's Carbon Border Adjustment Mechanism (CBAM), designed to prevent European industries from being undercut by cheaper, less environmentally friendly imports. China encourages the EU to avoid protectionist measures and green trade barriers and is willing to engage in multilateral discussions on green trade within the WTO framework. While China has ambitious green targets, it faces scrutiny for its pace and responsibility in addressing climate change. The EU plans to implement the carbon levy on high-carbon imports from 2026, insisting it complies with WTO rules. ***Source: REUTERS***

## The Global Economy Enters an Era of Upheaval

Global corporations are increasingly factoring "geopolitics" into their business strategies, with mentions of the term surging in corporate filings and earnings calls. This shift is driven by US-China tensions, the Ukraine conflict, and a growing emphasis on national interests. Companies are making investments in countries that align with their geopolitical interests, indicating a world reorganizing into rival blocs based on UN votes on Russia's invasion of Ukraine. While these changes are reshaping the global economic landscape, the economic consequences are still uncertain. Geopolitical factors are influencing trade, investments, and supply chains, potentially leading to inflation, less innovation, and increased global inequality. Despite the changes, the world remains interconnected, and economic relationships remain transactional, with countries and corporations eager to sell to one another. ***Source: Bloomberg***

## Re-Globalization for a Secure, Inclusive and Sustainable Future

The 2023 World Trade Report by the WTO examines the role of international trade in fostering a secure, inclusive, and sustainable global environment. The report underscores a strong multilateral trading system's importance in ensuring economic security, seen during the pandemic. It highlights trade's potential to enhance inclusivity and poverty reduction, stressing the need for supportive domestic policies. It also explores trade's role in addressing climate change within an extended integration framework. The WTO's role in promoting re-globalization, especially through agreements like the Trade Facilitation Agreement, is highlighted, emphasizing the importance of further reducing trade costs for developing countries in agriculture and services to achieve a secure, inclusive, and sustainable future. ***Source: WTO Blog***

## The Future of the WTO, Multilateral or Plurilateral?

In June 2022, the World Trade Organization (WTO) achieved a rare instance of success by finalizing several multilateral trade agreements, including waivers for COVID-19 vaccines, regulations on fisheries subsidies, a food security pact, and an extension of the e-commerce tariff moratorium. These agreements demonstrated the potential for collective action among the WTO's 164 member nations. However, amidst growing economic nationalism and a waning commitment to international cooperation, the WTO's ability to accomplish comprehensive trade liberalization through unanimous consensus appears limited. To preserve its commitment to multilateralism, the WTO must adopt a fresh approach. Rather than insisting on complete consensus for every agreement, the organization should encourage plurilateral agreements within its legal frameworkOver time, these plurilateral pacts could evolve into fully multilateral agreements encompassing all members. The idea is that partial successes can lead to broader consensus and acceptance. *Source:* ***CATO Institute***

### What Is the G20 and What Was Achieved at the Delhi Summit?

The G20, a group of countries representing 85% of global economic output and 75% of world trade, held a summit in Delhi, India. At the summit, the African Union was invited to become a permanent member, representing 55 African countries. The G20 was established in 1999 as a forum for finance ministers to address economic stability, later expanding its focus to include climate change and sustainable energy. Key outcomes of the Delhi summit included a joint declaration that condemned the impact of the Ukraine conflict on global food and energy security, though without direct criticism of Russia. A new network of railways and shipping routes was announced by the US, India, Saudi Arabia, and the EU to boost trade and counter China's Belt and Road Initiative. ***Source: BBC***

*សង្ខេបគោលនយោបាយ*

# ការវិភាគការបាត់បង់ស្បៀងអាហារ និងកាកសំណល់៖ មូលហេតុ ការបង្ការ និងការកាត់បន្ថយ

**លោកជំទាវ ចម និម្មល** *

*រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ឯកឧត្តម តាត ពុធសុធារី** * *

* *រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

***ខ្លឹមសារសំខាន់ៗ៖***

- ការបាត់បង់ស្បៀងអាហារ និងកាកសំណល់ ត្រូវបានគេមើលឃើញនៅក្នុងការគ្រប់គ្រង និងការបែកចែកជាផ្នែកមិនបានល្អ ទៅតាមខ្សែច្រវាក់តម្លៃកសិកម្ម
- នៅក្នុងប្រទេសដែលមានចំណូលមធ្យម និងខ្ពស់ ស្បៀងអាហារត្រូវបានខ្ជះខ្ជាយក្នុងការប្រើប្រាស់តាមផ្ទះខ្ពស់ជាងប្រទេសដែលមានចំណូលទាប
- នៅក្នុងប្រទេសដែលមានចំណូលទាប ស្បៀងអាហារត្រូវបានបាត់បង់យ៉ាងខ្លាំងនៅកម្រិតផលិតកម្ម និងការចែកចាយ
- ការបាត់បង់ស្បៀងអាហារ និងកាកសំណល់ បានដាក់សម្ពាធបន្ថែមទៀតលើការឡើងថ្លៃស្បៀងអាហារ និងការកើនឡើងនៃភាពអត់ឃ្លានជាសកល ការប្រយុទ្ធប្រឆាំងនឹងការបាត់បង់ស្បៀងអាហារ និងកាកសំណល់មានន័យថាជាការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លានជាសកល
- ការបាត់បង់ស្បៀងអាហារ និងកាកសំណល់ រួមចំណែកដល់ការកើនឡើងឧស្ម័នផ្ទះកញ្ចក់ជាសកល
- នៅកម្ពុជា មិនមានទិន្នន័យគ្រប់គ្រាន់ និងមានការខ្វះខាតទិន្នន័យក្នុងស្វែងយល់អំពីការបាត់បង់ស្បៀងអាហារ និងកាកសំណល់ក្នុងស្រុកទៅតាមប្រព័ន្ធស្បៀងអាហារ។ ដូច្នេះ ការសិក្សាស្រាវជ្រាវបន្ថែមទៀតក្នុងបញ្ហានេះគឺជារឿងបន្ទាន់យ៉ាងខ្លាំង។

## ១-សេចក្តីផ្តើម

ចំនួនប្រជាជនពិភពលោក ត្រូវបានគេប៉ាន់ប្រមាណថានឹងកើនឡើងដល់៩,៧ ប៊ីលាននាក់ នៅឆ្នាំ២០៥០ ហើយអាចឈានដល់កម្រិតខ្ពស់បំផុត១១ ប៊ីលាននាក់ នៅឆ្នាំ២១០០(UN 2019)[1]។ តម្រូវការជាសាកលសម្រាប់ស្បៀងអាហារ និងការប្រែប្រួលលំនាំនៃការប្រើប្រាស់ឆ្ពោះទៅរកផលិតផលស្បៀងអាហារ ដែលងាយរលួយបាន និងពឹងផ្អែកខ្លាំងលើធនធានច្រើន ត្រូវបានគេរំពឹងថានឹងកើនឡើង (ibid)។ ស្បៀងអាហារដែលមានតម្លៃសមរម្យ និងមានលទ្ធភាពប្រើប្រាស់បាន សម្រាប់ទាំងអស់គ្នាប្រកបដោយចីរភាព គឺជាបញ្ហាចម្បងមួយ ដែលពិភពលោកកំពុងប្រឈមមុខនាពេលបច្ចុប្បន្ននៅក្នុងទ្វីបអាស៊ី ដែលប្រជាជន ៥១៥ លាននាក់ត្រូវបានគេប៉ាន់ស្មានថាខ្វះអាហារូបត្ថម្ភ (Sahakian et al. 2020)[2] ។

ប្រជាជនជាង៣ ប៊ីលាននាក់នៅទូទាំងពិភពលោកមិនមានលទ្ធភាពទទួលបានរបបអាហារ ដែលផ្តល់សុខភាពល្អនោះទេ។ ប្រជាជនជិត៦៩០ លាននាក់ទទួលរងពីភាពអត់ឃ្លាន ខណៈដែលប្រជាជន២ ប៊ីលាននាក់ទទួលទានរបបអាហារមិនល្អ ដែលបណ្តាលឱ្យមានកង្វះសារជាតុចិញ្ចឹម និងរបបអាហារដែលទាក់ទងនឹងភាពធាត់លើសទម្ងន់ និងរបបអាហារដែលទាក់ទងនឹងជំងឺមិនឆ្លង ដូចជា ជំងឺបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល និងជំងឺទឹកនោមផ្អែម ដែលត្រូវបានគេប៉ាន់ស្មានថាមានចំនួន ១,៣ ទ្រីលានដុល្លារក្នុងមួយឆ្នាំ នៅឆ្នាំ២០៣០ (FAO 2022)[3]។ ការចំណាយសង្គមទាក់ទងនឹងរបបអាហារនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងគំរូរបបអាហារបច្ចុប្បន្នត្រូវបានប៉ាន់ប្រមាណថាមានចំនួន១,៧ ទ្រីលានដុល្លារក្នុងមួយឆ្នាំ នៅឆ្នាំ២០៣០ (ibid)។

---

[1] United Nations. 2019. "World Population Prospects 2019." Accessed October 25, 2022. https://www.un.org/development/desa/en/news/population/world-population-prospects-2019.html.

[2] Sahakian, Marlyne. 2020. "Apprehending Food Waste in Asia: Policies, Practices and Promising Trends." In Routledge Handbook of Food Waste, edited by Christian Reynolds, Tammara Soma, Charlotte Spring and Jordon Lazell, 187-206. London: Routledge.

[3] FAO. "Voluntary Code of Conduct for Food Loss and Waste Reduction." Accessed October 25, 2022. https://www.fao.org/3/cb9433en/cb9433en.pdf.

ជាមធ្យម ស្បៀងអាហារ ប្រមាណ ៣០-៤០% ត្រូវបានខាតបង់ ឬខ្ជះខ្ជាយ ជារៀងរាល់ឆ្នាំ។ បរិមាណដែលត្រូវបានបាត់បង់មានជាងមួយភាគបីនៃបរិមាណអាហារដែលត្រូវបានផលិតទាំងអស់ (ប្រមាណ២,៥ពាន់លានតោន) (FAO 2022a)[4]។ ទីបំផុត បញ្ហាបាត់បង់ និងខ្ជះខ្ជាយស្បៀងអាហារ ត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃ SDG (SDG 12.3)។ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយពាក់កណ្តាលនៃការខ្ជះខ្ជាយស្បៀងអាហារ នៅកម្រិតអ្នកលក់រាយ និងអ្នកប្រើប្រាស់ និងកាត់បន្ថយការខាតបង់ស្បៀងអាហារ តាមខ្សែច្រវាក់ផលិតកម្ម និងការផ្គត់ផ្គង់ រួមទាំងការបាត់បង់ក្រោយប្រមូលផលផងដែរ (FAO 2017)[5]។

វិធីសាស្ត្រនៃការវិភាគជាសកល លើការបាត់បង់ស្បៀងអាហារនិងកាកសំណល់ (FLW) មានគម្រោងប្រចាំឆ្នាំប្រមាណ ៣០% ផ្តោតលើធញ្ញជាតិ ប្រមាណ ៤០-៥០% ផ្តោតលើប្រភេទដំណាំយកមើម ផ្លែឈើ និងបន្លែ ប្រមាណ ២០% ផ្តោតលើដំណាំគ្រាប់ប្រេងដូង ប្រមាណ ៣៥% ផ្តោតលើត្រី និងអាហារសមុទ្រ និងប្រមាណ ១៥% ផ្តោតលើផលិតផលទឹកដោះគោ ដែលឆ្លងកាត់ការកែច្នៃកម្រិតបឋម និងក្រោយពេលប្រមូលផល សម្រាប់ចែកចាយ និងប្រើប្រាស់ (FAO 2011b)។ ជាចុងក្រោយ និន្នាការទូទៅនៃ រូបភាពទី១ បង្ហាញថា ម្ហូបអាហារភាគច្រើនបាត់បង់ក្នុងដំណើរការផលិតកម្មកម្រិតបឋម ខណៈដែល វិធីសាស្ត្រ FLW អាចត្រូវបានគេមើលឃើញនៅដំណាក់កាលប្រើប្រាស់ និងដំណាក់កាលក្រោយប្រមូលផល និងដំណាក់កាលចែកចាយ។ ជារៀងរាល់ឆ្នាំ ផ្លែឈើ និងបន្លែប្រមាណ ៤៥% ជុំវិញពិភពលោកត្រូវបានគេបោះចោល (Food Bank 2022)[6]។

## ២-វិធីសាស្ត្រនៃការវិភាគ FLW

គោលគំនិតនៃការបាត់បង់ និងខ្ជះខ្ជាយស្បៀងអាហារ ត្រូវបានកំណត់ឡើងក្នុងបរិបទផ្សេងៗគ្នា។ កង្វះខាតមូលដ្ឋានរួមសម្រាប់អនុវត្ត។ ឯកសារនេះ ពាក្យខាងក្រោមត្រូវបានកំណត់និយមន័យដោយអង្គការ FOA (FAO 2019)[7]។ ដូច្នេះ អ្នកនិពន្ធប្រើពាក្យទាំងនេះដើម្បីយល់ពីលំហូរនៃវិធីសាស្ត្រវិភាគ FLW នៅដំណាក់កាលក្រោយការប្រមូលផល និងដំណាក់កាលលក់រាយ ការផ្តល់សេវាម្ហូបអាហារ និងកម្រិតអ្នកប្រើប្រាស់តាមខ្សែច្រវាក់តម្លៃកសិកម្ម (សូមមើលរូបភាពទី២)។

- ស្បៀងអាហារ សំដៅទៅលើសារធាតុណាមួយ មិនថាឆ្លងកាត់ការកែច្នៃ ពាក់កណ្តាលកែច្នៃ ឬឆៅ សម្រាប់បម្រើដល់ការប្រើប្រាស់របស់មនុស្ស។
- ការបាត់បង់ស្បៀងអាហារ គឺជាការថយចុះនៃបរិមាណ ឬគុណភាពអាហារដែលកើតចេញពីការសម្រេចចិត្ត និងសកម្មភាពរបស់អ្នកផ្គត់ផ្គង់អាហារនៅក្នុងខ្សែច្រវាក់ផលិត ដោយមិនរាប់បញ្ចូលការលក់រាយ អ្នកផ្តល់សេវាម្ហូបអាហារ និងអ្នកប្រើប្រាស់។
